# ឯកឧត្តមទេសរដ្ឋមន្ត្រី ទទួលជួបពិភាក្សាជាមួយលោក Leslie Chan អ្នកពិគ្រោះយោបល់អន្តរជាតិ ABBA



ព្រឹកថ្ងៃទី ០៥ ឧសភា ឆ្នាំ ២០១៦ ឯកឧត្តម ចម ប្រសិទ្ធ ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម បានទទួលជួបពិភាក្សាជាមួយលោក Leslie Chan អ្នកពិគ្រោះយោបល់អន្តរជាតិ នៃក្រុមហ៊ុនពិគ្រោះយោបល់ ABBA Consultant Pte. Ltd នៃប្រទេសសឹង្ហបុរី ដើម្បីពិភាក្សាលំឥតអំពីកិច្ចការដែលភាគីទាំងពីរបានពិភាក្សារួចហើយ កាលពីជាងពីរ ខែមុន ទាក់ទងនឹងការអភិវឌ្ឍន៍ធនធានមនុស្ស-គម្រោងសាងសង់វិទ្យាស្ថានបណ្តុះបណ្តាលជំនាញឯកទេស និងការងារប្រព្រឹត្តិកម្មទឹកស្អាត ព្រមទាំងពិភាក្សាការងារថ្មីៗថែមមួយចំនួនទៀត មានដូចជា: គម្រោងតបណ្តាញទឹកស្អាតផ្គត់ផ្គង់តំបន់មាត់សមុទ្រកម្ពុជា-ការទទួលបានហិរញ្ញប្ប ទានសម្រាប់វិស័យទឹកស្អាតឯកជន-ការបំពាក់ផ្ទាំង សូឡា ដើរដោយពន្លឺព្រះអាទិត្យ និងការកែឆ្នៃកាកសំណល់សម្រាមក្នុងរាជធានីភ្នំពេញ បំលែងជាថាមពលអគ្គិសនីដើម្បីបានអគ្គិសនីបម្រើឲ្យរោងចក្រប្រព្រឹត្តិកម្មទឹកស្អាត ។ តាមរយ: ការពិភាក្សារួចមក តំណាងភាគីក្រុមហ៊ុនពិគ្រោះយោបល់សឹង្ហបុរីបានឯកភាពគ្រប់ចំណុចខាងលើ ហើយនឹងយកបញ្ហានេះ ទៅពិភាក្សាជាមួយថ្នាក់ដឹកនាំ និងដៃគូរបស់ខ្លួន ដើម្បីឈានទៅធ្វើការសិក្សាសមិទ្ធិលទ្ធភាពលើគម្រោងខាងលើនេះ ។



